# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ......២៥៨......ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួល និងអនុវត្តការអភិវឌ្ឍជំនាញ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការតម្រង់ទិសវិជ្ជាជីវៈ

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួល និងអនុវត្តការអភិវឌ្ឍជំនាញ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការតម្រង់ទិសវិជ្ជាជីវៈដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. ឯកឧត្តម | **អ៊ិត** | **សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សហប្រធាន |
| ២. ឯកឧត្តម | **ហង់** | **ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សហប្រធាន |
| ៣. ឯកឧត្តម | **ពេជ** | **សោភ័ន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៤. ឯកឧត្តម | **អ៊ឹម** | **កុច** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥. ឯកឧត្តម | **យក់** | **ឌុំយ** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៦. ឯកឧត្តម | **ប៉ុក** | **ប៉ាន់** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៧. ឯកឧត្តម | **ឡៅ** | **ហ៊ីម** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨. ឯកឧត្តម | **តូច** | **ធឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩. ឯកឧត្តម | **ម៉ក់** | **ខយ** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០. ឯកឧត្តម | **ពុត** | **សាមិត្ត** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១. ឯកឧត្តម | **ហុង** | **ធឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ គណៈកម្មាធិការជាតិបណ្តុះបណ្តាល | សមាជិក |
| ១២. ឯកឧត្តម | **ម៉ុន** | **តារិន** | នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣. ឯកឧត្តម | **ហេង** | **សួរ** | នាយកខុទ្ទកាល័យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤. លោក | **តឹប** | **អឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥. លោក | **ហួ** | **ឈុនគ្រី** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

១៦. លោក **ឃិន ចន្ថា** ប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
១៧. លោក **គង់ ត្នមិភា** ប្រធាននាយកដ្ឋានឧត្តមសិក្សា
ក្រសួងអប់រំ យុវជន និងកីឡា សមាជិក
១៨. លោក **សុកខុន ដាវីដ** ប្រធាននាយកដ្ឋានធានាគុណភាព
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
១៩. លោក **ហ៊ីង ស៊ីដេត** ប្រធាននាយកដ្ឋានបណ្តុះបណ្តាល
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២០. លោកស្រី**នង កណ្ណិកា** ប្រធាននាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២១. លោក **ទាង សាក់** ប្រធាននាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២២. លោកស្រី **សៅ សុគន្ធកេត្យា** ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២៣. លោក **ត្រី ស៊ាងឡុង** ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
ក្រសួងអប់រំ យុវជន និងកីឡា សមាជិក
២៤. លោក **ស៊ុន ប៊ុណ្ណា** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា
ក្រសួងអប់រំ យុវជន និងកីឡា សមាជិក
២៥. លោក **ឈិន ឌិត** អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
ក្រសួងអប់រំ យុវជន និងកីឡា សមាជិក
២៦. លោក **តាន់ សម្បត្តិ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២៧. លោក **សា ភិន្នមិឌី** អនុប្រធាននាយកដ្ឋានគោលនយោបាយ និង
យុទ្ធសាស្ត្រ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២៨. លោក **តុង ម៉េងអាង** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខាធិការ
២៩. លោក **សេង សុខហេង** អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន
ទីភ្នាក់ងារជាតិមុខរបរ និងការងារ លេខាធិការ
៣០. លោក **ខែ៉ត សុផលរឹទ្ធិ** ប្រធានការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈវិជ្ជាជីវៈ
ក្រសួងអប់រំ យុវជន និងកីឡា លេខាធិការ

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួងមានភារកិច្ចដូចខាងក្រោម៖

- កំណត់ជំនាញដែលគាំទ្រដល់ដំណើរការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា

- ជំរុញការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ផ្គត់ផ្គង់តម្រូវការគ្រប់វិស័យ ជាពិសេស វិស័យឧស្សាហកម្មដែលមានស្រាប់ និងឧស្សាហកម្មថ្មីនាពេលអនាគត
- កំណត់ និងបែងចែកភារកិច្ចរវាងក្រសួងទាំងពីរក្នុងការបណ្តុះបណ្តាល ឬអប់រំដំបូងដល់សិក្ខាកាម សិស្ស និស្សិតដែលមិនទាន់ចូលទីផ្សារការងារ និងការបណ្តុះបណ្តាល ឬអប់រំបន្តដល់អ្នកដែលកំពុងស្ថិតនៅក្នុងទីផ្សារការងារ ក៏ដូចជាបង្កការងាយស្រួលដល់កម្មវិធីបណ្តុះបណ្តាល ឬអប់រំមួយជីវិត
- បញ្ជ្រាបព័ត៌មាន និងតម្រង់ទិសវិជ្ជាជីវៈដល់សិស្សមធ្យមសិក្សា
- ពិនិត្យ និងពិគ្រោះយោបល់លើកម្មវិធីសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សាសំដៅធានានូវប្រសិទ្ធភាពនៃការវិនិយោគរបស់ថវិកាជាតិ
- គ្រប់គ្រង និងកំណត់គោលនយោបាយផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីរាជការក្របខណ្ឌគ្រូអប់រំ និងគ្រូអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យបានដូចគ្នា
- សិក្សា និងកំណត់ឲ្យបានច្បាស់លាស់នូវស្តង់ដាគុណវុឌ្ឍិបណ្តុះបណ្តាល និងអប់រំ របស់ក្រសួងទាំងពីរ
- សិក្សាលទ្ធភាពបង្កើតបន្ថែម ឬបង្កើនការគាំទ្រដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលស្ថិតនៅក្បែរតំបន់សេដ្ឋកិច្ចពិសេស
- ពិនិត្យលទ្ធភាពគាំទ្រ និងបង្កើនការចូលរួមរបស់វិស័យឯកជនក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជំនាញ
- ពិនិត្យយន្តការជ្រើសរើសសិស្សគ្មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឲ្យចូលរៀនបរិញ្ញាបត្ររង ឬសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ហើយបន្ទាប់មកឲ្យចូលរៀនឆ្នាំទី៣ ឧត្តមសិក្សា
- រៀបចំយន្តការវាយតម្លៃទទួលស្គាល់ និងផ្ទេរការសិក្សាទៅវិញទៅមករវាងសិក្ខាកាម សិស្ស និស្សិតនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថានមធ្យមសិក្សា ឬឧត្តមសិក្សា
- សហការបង្កើតទិន្នន័យរួមគ្រប់គ្រងធនធានមនុស្សដែលបានបណ្តុះបណ្តាល ឬអប់រំ និងធនធានមនុស្សដែលត្រូវបណ្តុះបណ្តាល ឬអប់រំបន្ត
- សិក្សាលទ្ធភាពប្រើប្រាស់គ្រូបច្ចេកទេស និងឯកទេស គ្រូអប់រំចំណេះទូទៅ និងគ្រូឧត្តមសិក្សារបស់រដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា

-ពិភាក្សាលើបញ្ហាផ្សេងៗទៀតដែលទាក់ទងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់របស់សហប្រធានក្រុមការងារ។

**ប្រការ៣ .-**

ក្រុមការងារអន្តរក្រសួង ត្រូវមានរបបប្រជុំយ៉ាងយូរ ៦ (ប្រាំមួយ)ខែម្តង។ សហប្រធានក្រុមការងារ អាចកោះប្រជុំបន្ថែមតាមការចាំបាច់។

សហប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានក្រុមការងារនៃស្ថាប័នរបស់ខ្លួនដឹកនាំកិច្ចប្រជុំ និងការងារ ប្រចាំរបស់ក្រុមការងារ។

សហប្រធានក្រុមការងារអាចអញ្ជើញតំណាងអង្គភាពពាក់ព័ន្ធចំណុះក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡាមកចូលរួមប្រជុំបាន។

ក្រុមការងារអន្តរក្រសួងអាចបង្កើតអនុក្រុមការងារបច្ចេកទេសជាសេនាធិការតាមការចាំបាច់។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គ នាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋាន អប់រំ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ